ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ២៨០.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
វិធានការក្នុងការបង្ការនិងគ្រប់គ្រងការចម្លងមេរោគអេដស៍ តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS)
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះ កំណត់អំពីវិធានការក្នុងការបង្ការនិងគ្រប់គ្រងការចម្លងមេរោគអេដស៍តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ ដើម្បីបញ្ឈៀសការចម្លងមេរោគអេដស៍ពីអ្នកទទួលសេវាម្នាក់ទៅម្នាក់ទៀត ដោយសារឧបករណ៍មិនស្អាត ការប្រើប្រាស់ឈាម ជាលិកា វត្ថុធាតុរាវ សរីរាង្គមិនល្អ ដោយការធ្វេសប្រហែសរបស់អ្នកផ្តល់សេវា។

មាត្រា២ .-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍និងជំងឺអេដស៍តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ នៅតាមៈ

- មន្ទីរពេទ្យ គ្លីនិក មន្ទីរពិសោធន៍អមវេជ្ជសាស្ត្ររដ្ឋនិងឯកជន
- មូលដ្ឋានមិនមែនសុខាភិបាលរួមមាន កន្លែងកែសម្ផស្ស អប់សព ចាក់សាក់ ឬការងារដទៃទៀតដែលមានលក្ខណៈស្រដៀងគ្នា។

ជំពូកទី២
វិធានការក្នុងការបង្ការការចម្លងមេរោគអេដស៍

មាត្រា៣ .-

វិធានការក្នុងការបង្ការការចម្លងមេរោគអេដស៍ តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ មានដូចអាទិ៍ៈ

- ត្រូវអនុវត្តវិធានការអនាម័យត្រឹមត្រូវតាមក្បួនវេជ្ជសាស្ត្រលើសម្ភារៈប្រើប្រាស់ចំពោះគ្រប់កន្លែងប្រកបរបរមិនមែនសុខាភិបាលរួមមាន កន្លែងកែសម្ផស្ស កន្លែងចាក់សាក់ អប់សព ឬកន្លែងដទៃទៀតដែលប្រកបរបរមានលក្ខណៈស្រដៀងគ្នា
- ត្រូវធ្វើតេស្តរកមេរោគអេដស៍បញ្ជាក់ជាមុនចំពោះគ្រប់មន្ទីរពិសោធន៍ឬអង្គភាពដែលយកឈាមជាលិកាឬសរីរាង្គទុកសម្រាប់ប្រើប្រាស់
- ត្រូវធ្វើតេស្តរកមេរោគអេដស៍បញ្ជាក់ជាមុនចំពោះរាល់ការប្រើប្រាស់ឈាម ជាលិកា ឬសរីរាង្គ។

ជំពូកទី៣
វិធានការក្នុងការគ្រប់គ្រងឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ

មាត្រា៤ .-

ការគ្រប់គ្រងឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រនៅតាមមន្ទីរពេទ្យ គ្លីនិក មន្ទីរពិសោធន៍អមវេជ្ជសាស្ត្ររដ្ឋនិងឯកជន ព្រមទាំងមូលដ្ឋានមិនមែនសុខាភិបាល ត្រូវអនុវត្តតាមគោលការណ៍ណែនាំស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខភាពរបស់ក្រសួងសុខាភិបាល។

ជំពូកទី៤
ការតាមដានត្រួតពិនិត្យ

មាត្រា៥ .-

ការតាមដានត្រួតពិនិត្យការអនុវត្តអនុក្រឹត្យស្តីពីវិធានការក្នុងបង្ការនិងគ្រប់គ្រងការចម្លងមេរោគអេដស៍តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាលនិងអង្គភាពជំនាញពាក់ព័ន្ធ ដើម្បីធ្វើការតាមដានត្រួតពិនិត្យការអនុវត្តវិធានការក្នុងបង្ការនិងគ្រប់គ្រងការចម្លងមេរោគអេដស៍តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ។

ជំពូកទី៥
ទណ្ឌកម្ម

មាត្រា៦ .-

បុគ្គលណាដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៣និងមាត្រា៤នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS)។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា៧ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៨ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ កើត ខែ ឫស្ភ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០២២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង ម៉ូលី

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ